ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងការពារជាតិ
លេខ : ០០១/សរ.ន.៦
២០០៥

រាជធានីភ្នំពេញ ថ្ងៃទី០៦ ខែមករា ឆ្នាំ២០០៥

# សារាចរណែនាំ
## ស្តីពីការចេញប័ណ្ណ និងផ្លាកលេខសំគាល់យានជំនិះគ្រប់ប្រភេទ
## ក្នុងកងយោធពលខេមរភូមិន្ទ

យោងអនុក្រឹត្យលេខ ៧៧ អន.ក្រ.បក ចុះថ្ងៃទី ២៨ ខែ វិច្ឆិកា ឆ្នាំ ២០០៣ ស្តីពីការចេញផ្លាកលេខសំគាល់យានជំនិះ និងអនុវត្តតាមសេចក្តីសំរេចលេខ ០៤២/០៤ ស.ស.រ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ២០០៤ ស្តីពីការចេញប័ណ្ណអាវុធខ្លី ផ្លាកលេខសំគាល់សំភារៈសឹក ប័ណ្ណបើកបរ ប័ណ្ណសំគាល់ និងផ្លាកលេខយានយន្តគ្រប់ប្រភេទរបស់ក្រសួងការពារជាតិ ដើម្បីបង្កការងាយស្រួលក្នុងការគ្រប់គ្រង បែងចែកច្បាស់លាស់នូវប្រភេទយានយន្ត យានជំនិះ លេខកូដសំរាប់សំគាល់ស្ថាប័នកងឯកភាព និងធានាបាននូវសន្តិសុខ សណ្តាប់ធ្នាប់ របៀបរៀបរយសង្គម ព្រមទាំងការប្រើប្រាស់ផ្លាកលេខចរាចរបានត្រឹមត្រូវ ស្របតាមតម្រូវការចាំបាច់របស់កងយោធពលខេមរភូមិន្ទ ក្រសួងការពារជាតិសូមធ្វើការណែនាំដូចខាងក្រោម :

១- ប័ណ្ណ និងផ្លាកលេខសំគាល់យានជំនិះគ្រប់ប្រភេទ របស់កងយោធពលខេមរភូមិន្ទ សំរាប់ប្រើប្រាស់បំរើការងារការពារជាតិ និងនៅសមរភូមិ យានជំនិះដែលបានមកដោយប្រើប្រាស់ថវិការដ្ឋ ត្រូវពាក់លេខរដ្ឋ យានជំនិះដែលបានមកដោយថវិកាឯកជន ត្រូវពាក់ផ្លាកលេខឯកជន យានជំនិះមួយគ្រឿងមានលេខសំគាល់ ( លេខចុះបញ្ជី ) តែមួយគត់ លេខសំគាល់នេះត្រូវប្រើប្រាស់រហូតដល់យានជំនិះខូច មិនអាចជួសជុលបាន ( គុណភាពពកិត ៥ ) លេខសំគាល់អាចប្តូរបានលុះត្រាតែយានជំនិះត្រូវបានផ្លាស់ប្តូរស្ថាប័នកងឯកភាព ។

២- យានជំនិះរបស់កងយោធពលខេមរភូមិន្ទ ត្រូវបានបែងចែកជា ៧ ប្រភេទគឺ :

- ប្រភេទទី ១ : ទោចក្រយានយន្ត ត្រីចក្រយានយន្ត
- ប្រភេទទី ២ : រថយន្តតូច
- ប្រភេទទី ៣ : រថយន្តដឹកជញ្ជូនធុនស្រាល និងធុនធ្ងន់
- ប្រភេទទី ៤ : យានយន្តឧបករណ៍
- ប្រភេទទី ៥ : ក្បាលរថយន្តសណ្តោង , រ៉ឺម៉ក ,សឺមីរ៉ឺម៉ក

- ប្រភេទទី ៦ : គ្រឿងយន្តវិស្វកម្ម
- ប្រភេទទី ៧ : គ្រឿងយន្តកសិកម្ម

៣- លេខកូដសំគាល់ស្ថាប័នកងឯកភាពមាន ១០ ប្រភេទ :

- ក្រសួងការពារជាតិ លេខកូដសំគាល់លេខ ១
- អគ្គបញ្ជាការដ្ឋាន លេខកូដសំគាល់លេខ ២
- យោធភូមិភាគ ១ លេខកូដសំគាល់លេខ ៣
- យោធភូមិភាគ ២ លេខកូដសំគាល់លេខ ៤
- យោធភូមិភាគ ៣ លេខកូដសំគាល់លេខ ៥
- យោធភូមិភាគ ៤ លេខកូដសំគាល់លេខ ៦
- យោធភូមិភាគ ៥ លេខកូដសំគាល់លេខ ៧
- យោធភូមិភាគពិសេស លេខកូដសំគាល់លេខ ៨
- កងរាជអាវុធហត្ថលើផ្ទៃប្រទេស លេខកូដសំគាល់លេខ ៩
- ក្រុមបេសកកម្មយោធាបរទេស លេខកូដសំគាល់លេខ ១០

៤- លក្ខណៈសំគាល់ប័ណ្ណ និងផ្លាកលេខសំគាល់យានជំនិះគ្រប់ប្រភេទ :

* ប័ណ្ណសំគាល់ :

- ផ្ទៃ និង ពណ៌ : មានផ្ទៃពណ៌ខៀវខាងលើ ក្រហមខាងក្រោមចែកពាក់កណ្តាលស្មើ ។ អក្សរ និង លេខពណ៌ស ។
- អក្សរ និងលេខ : មានអក្សរ ជាភាសាខ្មែរ និងលេខឡាតាំង ។
- រូបសណ្ឋាន : មានរាងជាចតុកោណកែង ។

( ឧបសម្ព័ន្ធទី ១ )

* ផ្លាកលេខសំគាល់យានជំនិះ :

បន្ទះដែកសំរាប់ចាប់ភ្ជាប់ទៅនឹងយានយន្តមុខ-ក្រោយ

- ផ្ទៃ និងពណ៌ : មានផ្ទៃពណ៌ខៀវខាងលើ ក្រហមខាងក្រោម ចែកពាក់កណ្តាលស្មើ ។ អក្សរ និង លេខពណ៌ស ។
- អក្សរ និងលេខ : មានអក្សរជាភាសាខ្មែរ និងភាសាអង់គ្លេស ព្រមទាំងមានលេខកូដសំគាល់ស្ថាប័នកងឯកភាពនៅខាងលើ និងសំគាល់ប្រភេទយានជំនិះនៅដើមលេខចរាចរ ។
- រូបសណ្ឋាន : មានរាងជាចតុកោណកែង ។
- ទំហំ : ផ្លាកលេខខាងមុខ និងក្រោយមានទំហំខុសគ្នា ។

( ឧបសម្ព័ន្ធទី ២ )

* ផ្លាកសញ្ញាសំគាល់កងឯកភាព :

ជា Sticker សំរាប់បិទនៅសងខាងទ្វារខាងមុខយានយន្ត

- ផ្ទៃ និងពណ៌ : មានផ្ទៃពណ៌ខៀវខាងលើ ក្រហមខាងក្រោម ចែកពាក់កណ្តាលស្មើរូបសញ្ញា និង អក្សរពណ៌ស ។

- រូបសញ្ញានិងអក្សរ : មានរូបសញ្ញាសំគាល់ស្ថាប័នកងឯកភាពនៅចំកណ្តាលនិងមានអក្សរជាភាសាខ្មែរ សរសេរកោងនៅពីក្រោម ។

- រូបសណ្ឋាន : មានរាងជារង្វង់មូល ។

( ឧបសម្ព័ន្ធទី ៣ )

៥- លក្ខខ័ណ្ឌប្រើប្រាស់ :

- យានជំនិះគ្រប់ប្រភេទ ដែលជាទ្រព្យសម្បត្តិរបស់រដ្ឋ ហើយនឹងត្រូវចុះក្នុងបញ្ជីសារពើភ័ណ្ឌដូចជា យានជំនិះបានមកជាជំនួយ-រដ្ឋបំពាក់-អំណោយពីគ្រប់មជ្ឈដ្ឋាន រៀបចំតម្លើងកែច្នៃក្នុងប្រទេស ជួសជុលរៀបតម្លើង និងយានយន្តរបស់ក្រុមបេសកកម្មយោធាបរទេស ។

- គ្រប់យានជំនិះ ត្រូវពាក់ផ្លាកលេខចរាចរអោយបានត្រឹមត្រូវនៅផ្នែកខាងមុខ និងផ្នែកខាងក្រោយ។ ចំពោះយានយន្តដែលមានលក្ខណៈពិសេស ត្រូវពាក់ផ្លាកលេខសំគាល់យានយន្ត នៅទីកន្លែងមួយជាក់លាក់ ដែលងាយស្រួលក្នុងការមើល និងពិនិត្យ ។ មិនត្រូវធ្វើការច្នៃប្រឌិត តុបតែងលើផ្លាកលេខសំគាល់យានជំនិះ ដែលនាំអោយខុសពីលំនាំដើម ដែលបានកំណត់ ។

- ការចេញប័ណ្ណ និងផ្លាកលេខសំគាល់យានជំនិះ អាចធ្វើទៅបានលុះត្រាតែយានជំនិះទាំងនោះ ត្រូវបាននាំចូលមកក្នុងព្រះរាជាណាចក្រកម្ពុជា ដោយស្របច្បាប់ជាធរមាន និងត្រូវបានបំពេញកាតព្វកិច្ចពន្ធដារនៃការនាំចូលនោះសព្វគ្រប់ហើយ ។

- ចំពោះយានជំនិះខូចខាតមិនអាចប្រើប្រាស់បាន ( គុណភាពកំរិត ៥ ) ត្រូវរក្សាទុកក្នុងបញ្ជីគ្រប់គ្រង រហូតដល់មានសេចក្តីសំរេចពីក្រសួងការពារជាតិ ទើបអាចកាត់ចេញបាន យានជំនិះខាងលើនេះមិនត្រូវបាន ផ្តល់ប័ណ្ណ និងផ្លាកលេខសំគាល់យានជំនិះអោយប្រើប្រាស់ឡើយ ។

- ចំពោះយានជំនិះដែលធ្វើការផ្លាស់ប្តូរម៉ាស៊ីន ឬ តួយានជំនិះ ឬធ្វើអោយបាត់ប័ណ្ណ ផ្លាកលេខបាក់ ត្រូវធ្វើសំណើស្នើសុំជាថ្មី ដើម្បីកែសំរួលប័ណ្ណសំគាល់យានជំនិះថ្មីទៀត សំរាប់ប្រើប្រាស់អោយបានត្រឹមត្រូវតាមស្ថានភាពជាក់ស្តែងរបស់យានជំនិះ ។

៦- សមត្ថកិច្ចគ្រប់គ្រង :

- គ្រប់ស្ថាប័នកងឯកភាពត្រូវបំពេញបែបបទស្នើសុំប័ណ្ណសំគាល់និងផ្លាកលេខសំគាល់យានជំនិះគ្រប់ប្រភេទ គំរូថ្មីតាមសមត្ថកិច្ចជំនាញនិងបានទទួលស្គាល់របស់មេបញ្ជាការទទួលបន្ទុកការងារជំនាញរបស់ស្ថាប័នកងឯកភាព ឆ្លងតាមឋានានុក្រម មកអគ្គនាយកដ្ឋានសំភារៈបច្ចេកទេស ក្រសួងការពារជាតិ ។

- អគ្គនាយកដ្ឋានសំភារៈបច្ចេកទេស ក្រសួងការពារជាតិ មានភារៈកិច្ចគ្រប់គ្រង ពិនិត្យសំណើស្នើ និងផ្តល់ជូននូវប័ណ្ណ និងផ្លាកលេខសំគាល់យានជំនិះគ្រប់ប្រភេទរបស់កងយោធពលខេមរភូមិន្ទជាបន្ត ។

- អគ្គនាយកដ្ឋានសំភារៈបច្ចេកទេស មានភារៈកិច្ចធ្វើសេចក្តីរាយការណ៍ជូនក្រសួងការពារជាតិ អំពីស្ថិតិយានជំនិះដែលប្រើប្រាស់ផ្លាកលេខសំគាល់របស់កងយោធពលខេមរភូមិន្ទ ។

ទទួលបានសារាចរណែនាំនេះ អគ្គមេបញ្ជាការនៃកងយោធពលខេមរភូមិន្ទ អគ្គលេខាធិការក្រសួងការពារជាតិ អគ្គនាយក អគ្គនាយកដ្ឋានសំភារៈបច្ចេកទេស មេបញ្ជាការកងទ័ពទាំង ៣ ប្រភេទ មេបញ្ជាការកងរាជអាវុធហត្ថលើផ្ទៃប្រទេស អគ្គនាយក នាយក ប្រធានស្ថាប័នចំណុះក្រសួងការពារជាតិ និងអគ្គបញ្ជាការដ្ឋាន ត្រូវអនុវត្តតាមខ្លឹមសារខាងលើអោយបានសំរេចលទ្ធផលជាវិជ្ជមាន ។

ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រី

នាយឧត្តមសេនីយ៍ ទៀ-បាញ់ នាយឧត្តមសេនីយ៍ ញឹក-ប៊ុនឆៃ

<u>ផ្ញើជូន</u> :

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងមហាផ្ទៃ
- ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- ក្រសួងសាធារណការនិងដឹកជញ្ជូន

" ដើម្បីជូនជ្រាប "

- អគ្គមេបញ្ជាការ នៃកងយោធពលខេមរភូមិន្ទ
- អគ្គលេខាធិការក្រសួងការពារជាតិ
- អគ្គនាយកដ្ឋានសំភារៈបច្ចេកទេស
- មេបញ្ជាការកងទ័ពទាំង បី ប្រភេទ
- មេបញ្ជាការកងរាជអាវុធហត្ថ
- គ្រប់ស្ថាប័នកងឯកភាពចំណុះក្រសួង និងអគ្គបញ្ជាការដ្ឋាន

" ដើម្បីអនុវត្ត "

- ឯកសារ កាលប្បវត្តិ